២ពង្សាវតារក្សត្រ២:២៣-៤:៤៣

ពេលនេះ ហោរាអេលីសេធ្វើដំណើរឆ្ពោះទៅកាន់ភូមិបេត-អែលហើយ។

> **លោកក៏ចេញពីទីនោះឡើងទៅឯក្រុងបេត-អែល កាលលោកកំពុងតែឡើងតាមផ្លូវទៅ នោះមានពួកក្មេងជំទង់ប្រុសៗ ចេញពីទីក្រុងមក ពោលមើលងាយ ដល់លោកថា អាទំពែកអើយ ចូរឡើងទៅចុះ អាទំពែកអើយ ចូរឡើងទៅចុះ (២ពង្សាវតារក្សត្រ ២:២៣)។**

នៅក្នុងអត្ថបទនេះ យើងឃើញមានពួកក្មេងៗជំទង់ប្រុសៗ នាំគ្នាមើលងាយដល់ហោរាអេលីសេ។ ក្មេងទាំងនេះ មិនមែនជាពួកកូនក្មេងដែលមិនទាន់ដឹងក្តីទេ។ បើហោរាអេលីសេដាក់បណ្តាសាដល់ក្មេងដែលមិនទាន់ដឹងក្តី លោកពិតជាធ្វើទាស់ទទឹងជាមួយនឹងព្រះបន្ទូលរបស់ព្រះអង្គ ស្តីអំពីកូនក្មេងហើយ។ ក្នុងគម្ពីរម៉ាថាយ១៩:១៤ ព្រះអម្ចាស់យេស៊ូវមានបន្ទូលថា "...ទុកឱ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរស្ថានសួគ៌មានសុទ្ធតែមនុស្សដូចវារាល់គ្នា"។ ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ដល់កូនក្មេង ដែលមិនទាន់ដឹងក្តីខ្លាំងណាស់។

នៅម៉្តុំស្រុកកាដេស-បារនា សាសន៍អ៊ីស្រាអែលបដិសេធមិនព្រមចូលទៅក្នុងទឹកដីសន្យាទេ ដោយយកលេះថា "តើហេតុអ្វីបានជាព្រះយេហូវ៉ាទ្រង់នាំយើងមកក្នុងកន្លែងនេះ ឱ្យត្រូវស្លាប់ដោយដាវដូច្នេះ ហើយឱ្យប្រពន្ធកូនយើងទៅជារំពាគេផង ចុះបើយើងវិលត្រឡប់ទៅឯស្រុកអេស៊ីព្ទវិញ នោះតើមិនមានប្រយោជន៍ជាជាងទេឬអី" (ជនគណនា១៤:៣)។ ពួកសាសន៍អ៊ីស្រាអែលមិនហ៊ានអោយកូនទៅរស់នៅក្នុងទឹកដីសន្យាទេ ខ្លាចក្រែងកូនប្រពន្ធរបស់គេមានគ្រោះថ្នាក់។ ប៉ុន្តែ ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ជាមួយនឹងកូនក្មេងរបស់សាសន៍អ៊ីស្រាអែលជាងឪពុកម្តាយគេទៅទៀត។

ពាក្យក្មេងនៅក្នុងអត្ថបទដែលយើងកំពុងសិក្សានេះ ក្នុងភាសាហេព្រើរហៅថា "ណះអា ឬណះហា"។ ពាក្យនេះប្រើបរិយាយពីលោកអ៊ីសាកកាលមានអាយុម្ភៃប្រាំបីឆ្នាំ ប្រើសម្រាប់លោកយ៉ូសែប ពេលលោកមានអាយុសាមសិបប្រាំបួនឆ្នាំ។ មិនតែប៉ុណ្ណោះ ពាក្យនេះប្រើសម្រាប់ពួកក្មេងៗ នៅទីក្រុងសូដុំម ដែលមកធ្វើទុក្ខបុកម្នេញដល់គេហដ្ឋានរបស់លោកឡុត។ ចំណែកនៅក្នុងគម្ពីរ១ពង្សាវតារក្សត្រ១២:៨ ស្តេចរេហូបោមស្តាប់ដំបូន្មានរបស់ពួកក្មេងៗស្រករទ្រង់។ ក្មេងៗទាំងនោះជាភាសាហេព្រើរក៏ហៅថា "ណះអា ឬ ណះហា"ដែរ។ ពាក្យនេះ ក៏ប្រើនៅក្នុងគម្ពីរ២ពង្សាវតារក្សត្រ ២:២៣ ពេលដែលហោរាសាំយូអែលហៅកូនប្រុសលោកអ៊ីសាយទាំងអស់មក ដើម្បីជ្រើសរើសម្នាក់អោយឡើងធ្វើជាស្តេច។ ដូច្នេះ ពាក្យក្មេងនៅក្នុងអត្ថបទខាងលើ មិនមែនជាក្មេងដែលមិនទាន់ដឹងក្តីទេ ពោលគឺជាក្មេងដែលពេញវ័យចេះដឹងខុស ដឹងត្រូវ ដឹងល្អ ដឹងអាក្រក់ហើយ។ ក្មេងទាំងនោះនាំគ្នាមើលងាយដល់ហោរាអេលីសេ។ គេជា

សិស្សសាលា ដែលរៀននៅមហាវិទ្យាល័យរបស់ពួកហោរាក្មេងក្លាយ។ ម្យ៉ាងទៀត គេជាជនពាល ដែលនាំគ្នាមើលងាយដល់ហោរាអេលីសេ។ គេនាំគ្នាស្រែកចំអកអោយហោរាអេលីសេថា "អាទំពែកអើយ ចូរឡើងទៅចុះ! អាទំពែកអើយ ចូរឡើងទៅចុះ!" ក្មេងទាំងនោះដឹងថា ព្រះជាម្ចាស់បានលើកហោរាអេលីយ៉ាទាំងរស់ទៅនៅជាមួយនឹងព្រះអង្គ។ គេចំអកអោយហោរាអេលីសេថា "បើអាទំពែកឯងគ្រាន់បើណាស់ ម្ដេចក៏មិនហោះឡើងដូចហោរាអេលីយ៉ាដែរទៅ!" អ្នកមិនជឿដល់ព្រះយេស៊ូវ តែងតែមើលងាយដល់អ្នកជឿព្រះយេស៊ូវថា "បើឯងជឿព្រះយេស៊ូវ ហេតុអ្វីក៏ឯងមិនទៅនៅភូមិយេស៊ូវទៅ!" សម័យដើមក៏មានគេមើលងាយអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវ សម័យឥឡូវនេះ ក៏មានគេមើលងាយដែរ។

សាវ័កពេត្រុសបញ្ជាក់ថា នៅគ្រាចុងក្រោយបង្អស់ ក្មេងៗមានចិត្តពាលខ្លាំងណាស់។ នៅក្នុងគម្ពីរ២ពេត្រុស៣:៣-៤ លោកបញ្ជាក់ថា "...នៅជាន់ក្រោយនឹងមានមនុស្សចំអកមក ដែលគេដើរតាមសេចក្ដីប៉ងប្រាថ្នារបស់គេ ទាំងចំអកឡកឡឺយថា តើសេចក្ដីសន្យាពីព្រះអង្គយាងមកនៅឯណា ដ្បិតតាំងពីពួកឰយុកោដេកលក់ទៅ នោះគ្រប់ទាំងអស់នៅតែដដែល ដូចជាពីកំណើតលោកីយរៀងមកដែរ"។ នៅគ្រាចុងក្រោយ អ្នកមិនស្គាល់ព្រះ ចំអកឡកឡឺយអោយពួកអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវ ស្ដីអំពីដំណើរដែលទ្រង់យាងត្រឡប់មកផែនដីវិញ។ គេឡកថា "បើព្រះឯងយាងត្រឡប់មកវិញមែន ហេតុដូចម្ដេចបានជានៅអែរអង្គធ្វើអ្វី ចូរចេញពីភូមិ ពីស្រុកយើងទៅនៅជាមួយនឹងព្រះរបស់ឯងទៅ!" ពួកមនុស្សជំនាន់ដើមក៏មើលងាយដល់ពួកអ្នកជឿដល់ព្រះអម្ចាស់

យេស៊ូវ ពួកសម័យនេះ ក៏មើលងាយដល់អ្នកជឿព្រះអម្ចាស់យេស៊ូវ ស្តីអំពីដំណើរដែលទ្រង់យាងត្រឡប់មកផែនដីជាលើកទីពីរ។ ខ្ញុំសូមរំឭកគ្រូបង្រៀនព្រះបន្ទូលគ្រប់គ្នាអោយប្រយ័ត្ន ក្នុងការបង្ហាត់បង្រៀនគោលទ្ធិស្តីពីដំណើរដែលព្រះអម្ចាស់យាងត្រឡប់មកវិញ។ យើងមិនត្រូវប៉ាន់ស្មានថា ថ្ងៃនេះឬថ្ងៃនោះ ព្រះអង្គយាងមក ឬប្រកាន់ថាមានសញ្ញាដែលព្រះអម្ចាស់ទ្រង់យាងមកវិញ ដោយពិតប្រាកដខ្លាំងពេកនោះឡើយ។ ព្រះអម្ចាស់យេស៊ូវពិតជាយាងត្រឡប់មកវិញមែន។ ព្រះអង្គយាងមកតាមពេលវេលាដែលទ្រង់មានបន្ទូលបញ្ជាក់នៅក្នុងព្រះបន្ទូលរបស់ទ្រង់។ យើងត្រូវបង្ហាត់បង្រៀនគោលទ្ធិនេះ អោយត្រូវជាមួយនឹងព្រះបន្ទូលរបស់ព្រះអង្គ ដើម្បីកុំអោយគេយកឱកាសមើលងាយដល់ជំនឿ និងសេចក្តីសង្ឃឹមរបស់យើង។ ហេតុការណ៍ដែលកើតឡើងនៅក្នុងអត្ថបទខាងលើ សម្តែងអំពីរូបភាពនៃការជំនុំជំរះ នៅពេលដែលព្រះជាម្ចាស់យាងត្រឡប់មកផែនដីវិញ។ អ្នកណាដែលចំអកឡកឡឺយពីរឿងព្រះអម្ចាស់យេស៊ូវយាងត្រឡប់មកវិញ អ្នកនោះប្រាកដជាមានវាសនាដូចក្មេងជំទង់ប្រុសៗ ចំនួនសែសិបពីរនាក់នោះជាមិនខាន។

> **លោកក៏បែរមើលមកក្រោយឃើញ ហើយដាក់បណ្តាសាដល់វា ដោយនូវព្រះនាមព្រះយេហូវ៉ា ស្រាប់តែមានខ្លាឃ្មុំញី២ ចេញពីព្រៃមក ហែកក្មេងទាំងនោះ អស់៤២នាក់ទៅ (២ពង្សាវតារក្សត្រ២:២៤)។**

គ្រូអធិប្បាយណាដែលបដិសេធមិនទទួលស្គាល់ថា ព្រះអម្ចាស់យេស៊ូវជាព្រះ ព្រមទាំងបដិសេធកិច្ចការដែលទ្រង់បានបំពេញ ក្នុងពេលដែលទ្រង់យាងមកលើកទីមួយ គ្រូអធិប្បាយទាំងនោះ ក៏ត្រូវជួបប្រទះជាមួយនឹងវាសនាដ៏អភ័ព្វដូចក្មេងជំទង់សែសិបពីរនាក់ នៅពេលដែលព្រះអម្ចាស់យេស៊ូវយាងមកជាលើកទីពីរដែរ។

ម្យ៉ាងទៀត សូមយើងកត់ចំណាំថា លោកអេលីសេជាមនុស្សមានក្បាលទំពែក។ បើអ្នកបម្រើព្រះអង្គណាដែលមានក្បាលទំពែក សូមកុំអោយអាក់អន់ចិត្តអោយសោះ ពីព្រោះហោរាអេលីសេក៏មានក្បាលទំពែកដែរ។ ខ្ញុំមានលក្ខណៈម្យ៉ាងដូចលោកអេលីសេ គឺមានក្បាលទំពែកដូចគាត់ដែរ។ ខ្ញុំមិនហ៊ានប្រៀបធៀបខ្លួនខ្ញុំជាមួយលោកអេលីសេពីរឿងអ្វីផ្សេងទៀតទេ។

ក្មេងជំទង់ទាំងសែសិបពីរនាក់នោះ ត្រូវខ្លាឃ្មុំញីពីរចេញមកហែកអស់ទៅ បន្ទាប់ពីលោកអេលីសេដាក់បណ្តាសាដោយនូវព្រះនាមព្រះយេហូវ៉ា។ នៅក្នុងព្រះបន្ទូលមានសម្តែងអំពីការជំនុំជំរះច្រើនកន្លែងណាស់។ ឯការជំនុំជំរះនោះទៀតសោត សុទ្ធតែកើតឡើងមកអំពីកិរិយាបះបោរទាស់ជាមួយនឹងព្រះបន្ទូលរបស់ទ្រង់។ ព្រះអម្ចាស់យេស៊ូវមានបន្ទូលថា វេទនាដល់ពួកអ្នកនៅទីក្រុងខូរ៉ាសីន និងពួកអ្នកទីក្រុងបេតសៃដា។ អ្នកទាំងនោះត្រូវទទួលរងវេទនាដោយសារគេឮព្រះបន្ទូលហើយ ប៉ុន្តែគេមិនយកចិត្តទុកដាក់នៅក្នុងចិត្តរបស់គេទេ (ម៉ាថាយ១១:២១)។ មិនតែប៉ុណ្ណោះ ព្រះអង្គមានបន្ទូលបន្ថែមទៀតថា អ្នកស្រុកកាពើណិម បើឯងមិនព្រមទទួលព្រះបន្ទូលដែលបានឮទេ ឯងនឹងត្រូវធ្លាក់ទៅនរកជាមិនខាន (ម៉ាថាយ១១:២៣)។ សេចក្តីទាំងនេះ

សម្តែងអំពីការជំនុំជំរះ។ សូមលោកអ្នកបងប្អូនកុំមើលស្រាលចំពោះសេចក្តីជំនុំជំរះរបស់ព្រះជាម្ចាស់ឡើយ។

បច្ចុប្បន្នយើងរស់នៅក្នុងសម័យមួយ ដែលពួកក្មេងជំទង់ៗបំពុលបរិយាកាសក្នុងការរស់នៅតាមភូមិស្រុក ខេត្ត ក្រុងនីមួយៗ។ ពួកក្មេងៗធ្វើការអាក្រក់ មានចាប់រំលោភ ប្លន់កំហែង កាប់សម្លាប់គ្នា បាញ់ប្រហារគ្នា ចាប់ជំរិតដូចយើងបានឃើញក្នុងសារពត៌មាន ឬស្តាប់ឮតាមវិទ្យុជាដើម។ យើងមិនដែលដេកមួយយប់ដោយមិនមានការភ័យខ្លាចក្រែងលោចោរប្លន់នោះទេ។ តើដល់កាលណាទៅ ទើបច្បាប់ចាត់ចែងបង្ក្រាបអំពើពាលយង់ឃ្នងរបស់ពួកក្មេងៗទាំងនោះ? ព្រះគម្ពីរសម្តែងថា អោយប្រើរំពាត់សម្រាប់វាយក្មេងៗ ដើម្បីអោយវារាងចាល។ បើយើងមានច្បាប់នៅក្នុងនគរត្រូវវាយក្មេងអាក្រក់ដោយរំពាត់ ព្រមទាំងអោយស្រែកអាក្រោសនៅទីសាធារណៈនោះកិរិយាប្រព្រឹត្តខូចអាក្រក់របស់ពួកក្មេងៗទាំងនោះ នឹងត្រូវថយចុះជាមិនខាន។ ពួកក្មេងៗជំទង់ដែលរស់នៅភូមិបេត-អែលមើលងាយដល់ហោរារបស់ព្រះ។ ខ្លាឃ្មុំញីពីរមកហែកគេអស់ទៅ។ ក្រោយពីពេលនោះមក ឥតមានជនណាដែលនៅភូមិបេត-អែល ហ៊ានក្អកជាមួយនឹងហោរាអេលីសេទៀត។ បើនរគររបស់យើងមានច្បាប់បង្ក្រាបក្មេងៗយ៉ាងដូច្នេះ នោះការបំពុលបរិយាកាសដែលបង្កើតឡើងដោយពួកក្មេងជំទង់ៗនឹងត្រូវចុះអន់ថយជាអតិបរមា។

# ជំពូក ៣ និង ៤

***ឆាទចនា*** *ព្រះជាម្ចាស់ប្រទានទឹកនិងជ័យជំនះ*

*ស្ត្រីមេម៉ាយម្នាក់ទទួលប្រេងយ៉ាងច្រើន*

*ស្ត្រីអារមួយរូបស្រុកស៊ូណែមប្រសូតបានកូនប្រុសមួយ*

*កូនប្រុសនាងស្ត្រីអារស្រុកស៊ូណែមមានជីវិតឡើងវិញ*

*បបរពុល*

*មនុស្ស១០០នាក់បរិភោគនំប៉័ងម្ភៃដុំឆ្អែតស្កប់ស្កល់*

**វីឯយ៉ូរ៉ាម ជាបុត្រអ័ហាប់ ទ្រង់ចាប់តាំងសោយរាជ្យលើពួកអ៊ីស្រា**
**អែលនៅក្រុងសាម៉ារី ក្នុងឆ្នាំទី១២នៃរាជ្យយ៉ូសាផាត ជាស្តេច**
**យូដា ក៏សោយរាជ្យបាន១២ឆ្នាំ (២ពង្សាវតារក្សត្រ៣:១)។**

ស្តេចយ៉ូរ៉ាម ត្រូវជាបុត្រាទីពីររបស់ស្តេចអ័ហាប់និងនាងយេសិបិល។ បុត្រាទីមួយនាមអ័ហាស៊ីយ៉ា ត្រូវស្លាប់ដោយគ្មានកូនណាស្នងត្រកូលទេ។

**២ ទ្រង់ប្រព្រឹត្តដំលាមកអាក្រក់នៅព្រះនេត្រព្រះយេហូវ៉ា តែមិន**
**ដល់ព្រះបិតា នឹងព្រះមាតាទ្រង់ទេ ដ្បិតទ្រង់បានបំបាត់រូបព្រះ**

**បាល ដែលព្រះបិតាទ្រង់បានធ្វើចេញ ៣ប៉ុន្តែ ទ្រង់នៅតែកាន់**
**តាមអំពើបាបរបស់យេរ៉ូបោម ជាកូននេបាត ដែលបាននាំឱ្យពួក**
**អ៊ីស្រាអែលធ្វើតាមផងនៅឡើយ ទ្រង់មិនបានលះបង់អំពើបាប**
**នោះទេ (២ពង្សាវតារក្សត្រ៣:២-៣)។**

ស្តេចយ៉ូរ៉ាមមិនបានប្រព្រឹត្តអំពើបាបអោយខ្លាំងក្លាដូចស្តេចអ័ហាប់ទេ។ ប៉ុន្តែ ស្តេចនេះនៅប្រព្រឹត្តអំពើបាបដូចស្តេចយេរ៉ូបោមនៅឡើយ ពោលគឺជាអំពើបាបដែលថ្វាយបង្គំព្រះគោមាស។

**៤វីឯមេសា ជាស្តេចសាសន៍ម៉ូអាប់ ទ្រង់ជាអ្នកមានហ្វូងចៀម**
**ច្រើន ហើយទ្រង់ក៏ឡើងសួយ ជារោមរបស់កូនចៀម១សែន នឹង**
**រោមរបស់ចៀមឈ្មោល១សែន មកថ្វាយស្តេចអ៊ីស្រាអែល ៥តែ**
**កាលអ័ហាប់ទ្រង់សុគតទៅ នោះស្តេចម៉ូអាប់បានបះបោរនឹង**
**ស្តេចអ៊ីស្រាអែល (២ពង្សាវតារក្សត្រ៣:៤-៥)។**

ស្តេចម៉ូអាប់ធ្លាប់ធ្វើជាចំណុះដល់នគរអ៊ីស្រាអែល ព្រមទាំងបង់សួយសារអាករជារៀងរាល់ឆ្នាំផង។ នៅពេលស្តេចអ័ហាប់ចូលទីវង្គត់ ស្តេចម៉ូអាប់បានរើបំរាស់ដើម្បីទាមទារសេរីភាព។ ស្តេចយ៉ូរ៉ាមបានប្រមូលកងទ័ពរបស់ទ្រង់ ព្រមទាំងចងសម្ព័ន្ធ

ជាមួយនឹងស្តេចយ៉ូសាផាត ដើម្បីវាយបង្ក្រាបស្តេចសាសន៍ម៉ូអាប់។ នៅពេលកំពុងលើកទ័ពទៅវាយស្តេចសាសន៍ម៉ូអាប់ ស្តេចយ៉ូរ៉ាម និងស្តេចយ៉ូសាផាត ព្រមទាំងកងទ័ពមិនមានទឹកទទួលទាន។ ស្តេចយ៉ូសាផាត ជាស្តេចដែលកោតខ្លាចដល់ព្រះជាម្ចាស់។ ទ្រង់ស្នើសូមអោយស្តេចយ៉ូរ៉ាមសួរដំបូន្មានដល់ហោរារបស់ទ្រង់។ ស្តេចទាំងពីរអង្គក៏ទៅសួរយោបល់ពីអេលីសេ ដែលជាហោរារបស់ព្រះ។ ហោរាអេលីសេបានបន្ទោសដល់ស្តេចយ៉ូរ៉ាមជាខ្លាំង។

> **[១៣]ឯអេលីសេ ក៏ទូលដល់ស្តេចអ៊ីស្រាអែលថា តើទ្រង់នឹងទូលបង្គំ
> ត្រូវការអ្វីនឹងគ្នា ចូរទៅឯពួកហោរារបស់ព្រះបិតា នឹងព្រះមាតា
> ទ្រង់ចុះ តែស្តេចអ៊ីស្រាអែលមានបន្ទូលតបថា ទេ ដ្បិតព្រះយេ
> ហូវ៉ាបានហៅស្តេចទាំង៣អង្គនេះមក ដើម្បីនឹងប្រគល់ទៅក្នុង
> កណ្តាប់ដៃ នៃពួកម៉ូអាប់ហើយ [១៤]រួចអេលីសេទូលថា ទូលបង្គំ
> ស្បថដោយនូវព្រះយេហូវ៉ា នៃពួកពលបរិវារ ដ៏មានព្រះជន្មរស់
> នៅ ដែលទូលបង្គំឈរនៅចំពោះទ្រង់នេះថា បើទូលបង្គំមិនបាន
> យល់ដល់យ៉ូសាផាត ជាស្តេចយូដា នោះប្រាកដជាទូលបង្គំមិន
> ព្រមទាំងក្រឡេកមើលទៅទ្រង់ ឬឃើញទ្រង់ទេ (២ពង្សាវតារ
> ក្សត្រ៣:១៣-១៤)។**

## ព្រះជាម្ចាស់ប្រទានទឹកនិងជ័យជំនះ

ព្រះជាម្ចាស់សន្យារួចហើយថា ទ្រង់នឹងប្រទានអោយស្តេចយ៉ូសាផាតមានជ័យជំនះ។ ទ្រង់ប្រទានអោយមានទឹកសម្រាប់កងទ័ពបរិភោគគ្រប់គ្រាន់ និងប្រទានអោយមានជ័យជំនះលើស្តេចសាសន៍ម៉ូអាប់ថែមទៀតផង។

សូមយើងកត់ចំណាំនូវមធ្យោបាយ ដែលព្រះជាម្ចាស់ប្រទានអោយស្តេចយ៉ូសាផាតមានជ័យជំនះដូចខាងក្រោមនេះ :

**ហើយលោកទាយថា ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ ចូរជីកប្រឡាយឱ្យពេញក្នុងច្រកភ្នំនេះទៅ (២ពង្សាវតារក្សត្រ៣:១៦)។**

ប្រឡាយទាំងអម្បាលមាណនោះ សម្រាប់តម្កល់ទឹកនៅពេលដែលព្រះជាម្ចាស់បញ្ជូនអោយមានទឹកហូរមកដល់ទីបោះទ័ពរបស់សាសន៍អ៊ីស្រាអែល។

**លុះព្រឹកឡើង នៅពេលថ្វាយដង្វាយ ក៏មានទឹកហូរមកពីខាងស្រុកអេដំម នោះច្រកភ្នំក៏មានទឹកពេញ (២ពង្សាវតារក្សត្រ៣:២០)។**

ពួកកងទ័ពសាសន៍ម៉ូអាប់កំពុងប្រមូលទ័ព ដើម្បីការពារនគររបស់ខ្លួន។ កំពុងតែត្រៀមទ័ពដើម្បីការពារ គេសម្លឹងឃើញកងទ័ពរបស់សាសន៍អ៊ីស្រាអែលកំពុងលើកទ័ពចូលមក។

**២២ ព្រឹកព្រហាមថ្ងៃនោះ ពួកម៉ូអាប់ក្រោកឡើងឃើញពន្លឺថ្ងៃចាំង**
**មកពីលើទឹក ដែលនៅមុខគេនោះ មើលទៅក្រហមដូចជាឈាម**
**២៣ គេក៏និយាយគ្នាថា នោះគឺជាឈាមហើយ ពួកស្តេចនោះបាន**
**ប្រហារជីវិតគ្នា ប្រាកដជាបានសំឡាប់គ្នានឹងគ្នា វិនាសអស់ហើយ ដូច្នេះ ឱពួកម៉ូអាប់អើយ ចូរយើងទៅរឹបជាន់ចាប់យករបឹបរបស់គេចុះ (២ពង្សាវតារក្សត្រ៣:២២-២៣)។**

សាសន៍ម៉ូអាប់ឃើញពណ៌ក្រហម ស្មានថាជាឈាមរបស់សាសន៍អ៊ីស្រាអែលហូរដោយសម្លាប់គ្នាឯង។ គេនាំគ្នាចូលតែខ្លួនទទេ ដើម្បីទៅប្រមូលជ័យភ័ណ្ឌ។ ហេតុការណ៍នោះ បណ្តាលអោយសាសន៍អ៊ីស្រាអែលមានប្រៀបលើពួកសាសន៍ម៉ូអាប់។

**២៦ កាលស្តេចម៉ូអាប់ឃើញថា ចំបាំងជាខ្លាំងទប់មិនបាន នោះទ្រង់រើសយកទាហាន៧០០នាក់ ដែលកាន់ដាវនាំទៅដោយប្រាថ្នា**
**នឹងទំលាយចូលទៅដល់ស្តេចអេដំម តែធ្វើមិនកើតទេ ២៧ រួចមក**

**ទ្រង់យកបុត្រាច្បង ដែលត្រូវសោយរាជ្យជំនួសទ្រង់ ទៅថ្វាយជាយញ្ញបូជាដុត នៅលើកំពែងក្រុង នោះក៏កើតមានសេចក្តីក្រេវក្រោធចំពោះពួកអ៊ីស្រាអែលជាខ្លាំង ហើយគ្រប់គ្នាថយចេញត្រឡប់ទៅស្រុកគេវៀងខ្លួនវិញ (២ពង្សាវតារក្សត្រ៣:២៦-២៧)។**

សាសន៍ម៉ូអាប់តែងតែយកមនុស្សទៅដុតដល់ព្រះកេម៉ុស ដើម្បីថ្វាយជាយញ្ញបូជា។ គេសង្ឃឹមថា ព្រះកេម៉ុសនឹងជួយបណ្តេញសត្រូវកុំអោយចូលមកលុកលុយដល់នគររបស់ខ្លួន។ ព្រះជាម្ចាស់ស្អប់អំពើដែលគេយកមនុស្សទៅដុតថ្វាយជាយញ្ញបូជា។ ព្រះអង្គបណ្តាលអោយសាសន៍អ៊ីស្រាអែលមានជ័យជំនះនៅលើសាសន៍ម៉ូអាប់ ដើម្បីបញ្ជាក់អោយដឹងថា ព្រះអម្ចាស់មិនពេញព្រះទ័យជាមួយនឹងអំពើប្រព្រឹត្តរបស់គេទេ។ ចំណែកឯសាសន៍អ៊ីស្រាអែលវិញ ទុកចិត្តលើព្រះជាម្ចាស់ដែលទ្រង់មានពេញដោយសេចក្តីមេត្តាករុណា និងសេចក្តីស្រឡាញ់។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ នៅក្នុងពេលនេះ ព្រះជាម្ចាស់បណ្តាលអោយសាសន៍អ៊ីស្រាអែលដកទ័ពថយត្រឡប់ទៅវិញ។ ទ្រង់ធ្វើយ៉ាងនោះ ពីព្រោះទ្រង់មិនពេញព្រះទ័យជាមួយនឹងអំពើបាបរបស់ស្តេចអ័ហាប់។ សាសន៍អ៊ីស្រាអែលដកទ័ពត្រឡប់ទៅវិញ មិនមែនដោយសារព្រះកេម៉ុសធ្វើអោយសាសន៍អ៊ីស្រាអែលមានការក្តៅក្រហាយទេ។ សាសន៍អ៊ីស្រាអែលត្រឡប់ទៅស្រុកគេវៀងខ្លួន ពីព្រោះព្រះជាម្ចាស់បណ្តាលអោយគេត្រឡប់ទៅវិញ ព្រោះទ្រង់មិនពេញព្រះទ័យ អោយសាសន៍អ៊ីស្រាអែលយកជ័យជំនះលើសាសន៍ម៉ូអាប់ទាំងស្រុង

ដោយព្រោះអំពើបាបរបស់ស្តេចអ័ហាប់។ ឥឡូវយើងឈានមកដល់ទីបញ្ចប់នៃគម្ពីរ២ពង្សាវតារក្សត្រជំពូក៣ហើយ។ សូមយើងសិក្សា២ពង្សាវតារក្សត្រជំពូក៤។ នៅក្នុងគម្ពីរ២ពង្សាវតារក្សត្រជំពូក៤ ហោរាអេលីសេបានធ្វើការអស្ចារ្យបួនយ៉ាង។ ការអស្ចារ្យទាំងអស់នោះ មានលក្ខណៈដូចការអស្ចារ្យដែលហោរាអេលីយ៉ាបានធ្វើដែរ តែការអស្ចារ្យដែលហោរាអេលីសេធ្វើមានលក្ខណៈទូលំទូលាយជាង។

## ស្ត្រីមេម៉ាយម្នាក់ទទួលបានប្រេងយ៉ាងច្រើន

**រីឯមានស្ត្រីម្នាក់ ជាប្រពន្ធនៃពួកសិស្ស របស់ពួកហោរាម្នាក់ នាងបានស្រែកដល់អេលីសេថា ប្ដីខ្ញុំ ជាអ្នកបំរើលោក បានស្លាប់ហើយ លោកក៏ជ្រាបថា អ្នកបំរើរបស់លោកបានកោតខ្លាចដល់ព្រះយេហូវ៉ាដែរ ឥឡូវនេះ ម្ចាស់បំណុលបានមក ចង់យកកូនខ្ញុំទាំង២ទៅធ្វើជាបាវបំរើ (២ពង្សាវតារក្សត្រ៤:១)។**

ហោរាអេលីសេស្គាល់ប្ដីរបស់ស្ត្រីមេម៉ាយម្នាក់នេះច្បាស់ណាស់ ពីព្រោះគាត់ជាអ្នកជឿដល់ព្រះអម្ចាស់មួយរូប យ៉ាងមុតមាំ។ បាវបម្រើព្រះអង្គមួយរូបនោះស្លាប់ទៅ បន្សល់ទុកអោយភរិយារបស់លោកបង់ប្រាក់ទាំងអម្បាលមាណដែលលោកនៅ

ជំពាក់គេ។ ភរិយាមេម៉ាយរបស់គ្រូគង្វាលមួយរូបនេះ មិនមានទ្រព្យធនណាយកទៅសងគេទេ ដូច្នេះ នាងចាំបាច់ត្រូវយករូបនាងផ្ទាល់ និងកូនរបស់នាងទៅសងដល់អ្នកដែលប្តីរបស់នាងបានជំពាក់លុយ។

**អេលីសេសួរនាងថា តើចង់ឱ្យខ្ញុំធ្វើអ្វីឱ្យអ្នក សូមប្រាប់ខ្ញុំចុះ តើអ្នកមានអ្វីនៅផ្ទះ នាងឆ្លើយតបថា នាងខ្ញុំគ្មានអ្វីនៅផ្ទះទេ មានតែដបប្រេង១ប៉ុណ្ណោះ (២ពង្សាវតារក្សត្រ៤:២)។**

ហោរាអេលីសេប្រាប់ថា លោកចាំបាច់ត្រូវជួយគ្រួសារគ្រូគង្វាលរូបនេះ មិនអោយទៅជាខ្ញុំគេឡើយ។ ក្រឹត្យវិន័យរបស់លោកម៉ូសេ ទាមទារអោយថែរក្សាដល់ស្ត្រីមេម៉ាយ និងកូនកំព្រា។

**[៣]ដូច្នេះ លោកប្រាប់ថា ចូរអ្នកចេញទៅខ្ចីភាជនៈ ពីពួកអ្នកជិតខាងទាំងប៉ុន្មាន គឺជាភាជនៈ ដែលនៅទទេ ហើយកុំឱ្យខ្ចីតិចឡើយ [៤]រួចឱ្យអ្នកនាំកូនចូលទៅក្នុងផ្ទះ បិទទ្វារទៅ ហើយចាក់ប្រេងទៅក្នុងភាជនៈទាំងនោះ កាលណាមាន១ណាពេញ នោះចូរដាក់ទុកទៅខាងម្ខាង [៥]ដូច្នេះ នាងក៏ចេញពីលោកទៅ នាំកូនចូលទៅក្នុងផ្ទះបិទទ្វារ កូនទាំង២ក៏ហុចភាជនៈមកឱ្យម្តាយ ហើយ**

**ម្តាយក៏ចាក់ប្រេងដាក់ (២ពង្សាវតារក្សត្រ៤:៣-៥)។**

គ្រួសារស្ត្រីមេម៉ាយរបស់គ្រូគង្វាលមួយរូបនេះ ទទួលបានប្រេងយ៉ាងច្រើននៅក្នុងផ្ទះរបស់នាង។

**៦ លុះភាជនៈទាំងនោះបានពេញហើយ នោះនាងបង្គាប់កូនថា ចូរ
ហុច១ទៀតមកឱ្យអញ តែកូនឆ្លើយតបថា មានតែប៉ុណ្ណឹងទេ នោះ
ប្រេងក៏ឈប់ហូរទៅ ៧ នាងក៏ទៅជំរាបដល់អ្នកសំណប់របស់ព្រះ
ហើយលោកប្រាប់ថា ចូរយកប្រេងនោះទៅលក់ សងបំណុលគេ
ទៅ ឯចំណែកដែលសល់នៅ នោះចូរទុកចិញ្ចឹមខ្លួននឹងកូនចុះ
(២ពង្សាវតារក្សត្រ៤:៦-៧)។**

ការអស្ចារ្យដែលហោរាអេលីសេបានធ្វើក្នុងពេលនេះ ធំធេងជាងការអស្ចារ្យដែលហោរាអេលីយ៉ាបានធ្វើដល់ស្ត្រីមេម៉ាយម្នាក់នៅភូមិសារិបតា។

## ស្រីអារមួយរូបស្រុកស៊ូណែមប្រសូតបានកូនប្រុសមួយ

ស្ត្រីអារមួយរូបនេះ រស់នៅក្នុងភូមិស៊ូណែម។ នាងហើយនឹងប្តីរបស់នាង

គ្មានកូនទេ។ នាងរៀបចំបន្ទប់មួយនៅផ្ទះរបស់នាង ហៅថា ជាបន្ទប់សម្រាប់ហោរារបស់ព្រះ។

**[៩]នាងក៏និយាយនឹងប្ដីថា មើល ខ្ញុំយល់ឃើញថា មនុស្សដែលតែង
ធ្លាប់មកផ្ទះយើង ជាញយៗនេះ លោកជាអ្នកបរិសុទ្ធរបស់ព្រះ
[១០]សូមឱ្យយើងធ្វើបន្ទប់១តូច នៅលើជញ្ជាំង ព្រមទាំងដាក់គ្រែ តុ
កៅអី នឹងជើងទៀន សំរាប់លោកផង ដូច្នេះ កាលណាលោក
មកផ្ទះយើង នោះនឹងនៅក្នុងបន្ទប់នោះ (២ពង្សាវតារក្សត្រ៤:
៩-១០)។**

នៅក្នុងប្រទេសដែលដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវ ជ្រួតជ្រាបនៅក្នុងចិត្តរបស់ប្រជាពលរដ្ឋ គេតែងតែសង់បន្ទប់មួយទុកសម្រាប់ពេលដែលគ្រូគង្វាល ឬបេសកជនមកលេងក្នុងភូមិស្រុករបស់គេ។ គ្រូគង្វាល ឬបេសកជនអាចប្រើបន្ទប់នោះដោយមិនអោយមានការខ្វាចរអែងអ្វីឡើយ។ យើងគួរមានទម្លាប់ទុកបន្ទប់មួយអោយទំនេរសម្រាប់គ្រូគង្វាល ឬបាវបម្រើរបស់ព្រះអង្គដែលមកពីទីជិតឆ្ងាយ ដើម្បីអោយសម្រាកនៅផ្ទះរបស់យើង។

ហោរាអេលីសេពេញចិត្តចំពោះ ការទទួលរាក់ទាក់របស់គ្រួសារនេះណាស់។ លោកចង់សងគុណដល់គេ តែមិនដឹងធ្វើដូចម្ដេច ក៏ហៅអ្នកបម្រើរបស់លោកម្នាក់

ឈ្មោះកេហាស៊ីមកសួរយោបល់។

**១៤ លោកសួរទៀតថា បើដូច្នេះ តើត្រូវសងគុណដល់នាងយ៉ាង**
**ណា កេហាស៊ីឆ្លើយឡើងថា មើលគាត់គ្មានកូនទេ ហើយប្តីក៏**
**ចាស់ផង ១៥ លោកប្រាប់ថា ចូរហៅនាងមកនេះ កាលបានហៅ**
**មកដល់ហើយ នោះនាងឈរនៅត្រង់មាត់ទ្វារ ១៦ ហើយលោក**
**ប្រាប់ថា ដល់កំណត់ ឆ្នាំក្រោយ នោះនាងនឹងបានបីកូនប្រុស១**
**តែនាងឆ្លើយថា ទេ លោកម្ចាស់ ជាអ្នកសំណប់របស់ព្រះអើយ**
**សូមកុំកុហកដល់នាងខ្ញុំឡើយ ១៧ ស្ត្រីនោះក៏មានទំងន់ ហើយដល់**
**កំណត់ឆ្នាំក្រោយ នាងសំរាលបានកូនប្រុស១ ដូចពាក្យដែល**
**អេលីសេបានប្រាប់ (២ពង្សាវតារក្សត្រ៤:១៤-១៧)។**

## កូនប្រុសនាងស្ត្រីអារស្រុកស៊ូណែមមានជីវិតឡើងវិញ

លុះកូននោះធំដឹងក្តី កូននោះក៏មានជំម្ងឺហើយស្លាប់ទៅ។ ហោរាអេលីសេបានប្រោសដល់ខ្មោចក្មេងនោះ អោយមានជីវិតឡើងវិញ។ លោកប្រើវិធីដូចហោរាអេលីយ៉ាបានប្រើដែរ ក្នុងការនាំក្មេងនោះអោយមានជីវិតឡើងវិញ។ វិធីដែលហោរាអេលីយ៉ាប្រើ មានរៀបរាប់នៅក្នុងគម្ពីរ១ពង្សាវតារក្សត្រជំពូល១៧។ ឯគោល

ការណ៍នៃការប្រោសមនុស្សស្លាប់អោយមានជីវិតឡើងវិញ គឺជាគោលការណ៍ដែលព្រះអម្ចាស់យេស៊ូវទ្រង់ប្រើយ៉ាងដូច្នោះដែរ។ មនុស្សយើងគ្រប់រូបត្រូវស្លាប់ក្នុងអំពើបាប និងអំពើរំលងរបស់យើង។ ដរាបណាមនុស្សមានបាបមិនបានប៉ះពាល់រូបកាយរបស់ព្រះអម្ចាស់យេស៊ូវ ដែលទ្រង់រស់ពីសុគតឡើងវិញទេ មនុស្សគ្រប់រូបនឹងស្លាប់ក្នុងអំពើរំលងរបស់ខ្លួនជានិច្ចនិរន្តរ៍តរៀងទៅ។ នៅក្នុងព្រះអម្ចាស់យេស៊ូវ មានជីវិត ព្រោះទ្រង់នោះហើយ ជាតួនៃជីវិតតែម្តង។

## បបរពុល

ហេតុការណ៍ទីបួន ដែលហោរាអេលីសេបានធ្វើនៅក្នុងជំពូក៤ គឺជាហេតុការណ៍ដែលលោកធ្វើអោយបបរពុល ក្លាយត្រឡប់ទៅជាអាហារដែលអាចទទួលទានបាន។ នៅគ្រានេះ ជាគ្រាដែលមានភាពរាំងស្ងួតយ៉ាងខ្លាំង។ សិស្សហោរាអេលីសេដាក់វេនគ្នា ដើម្បីទៅបេះស្លឹកឈើ ឬផ្លែឈើព្រៃយកមកដើម្បីបបរចែកសិស្សដទៃៗទៀតបរិភោគ។ សិស្សទាំងនោះសុទ្ធតែជាសិស្សដែលរៀននៅសាលាព្រះគម្ពីរ។ នៅពេលដែលសិស្សមួយក្រុមចេញទៅរកម្ហូបអាហារសម្រាប់សិស្សដទៃទៀត គេបានបេះផ្លែឈើដែលមានជាតិពុល។ គេយកស្លឹក និងផ្លែឈើព្រៃទាំងនោះ មកធ្វើជាបបរ។ នៅពេលដែលគេដួសទទួលទានទើបគេដឹងថា បបរនោះមានជាតិពុល។

**៤០ រួចគេដួសបបរនោះឱ្យគ្រប់គ្នាបរិភោគ តែកាលគេកំពុងតែបរិភោគ នោះក៏ស្រែកឡើងថា ឱអ្នកសំណប់របស់ព្រះអើយ បបរនេះពុលទេ ហើយគេបរិភោគពុំបាន ៤១ តែលោកប្រាប់ថា ដូច្នេះចូរយកម្សៅមកចុះ រួចលោកក៏ចាក់ទៅក្នុងថ្លាង ហើយប្រាប់ថា ចូរដួសចែកឱ្យគេបរិភោគទៅ នោះក៏គ្មានជាតិពុលនៅក្នុងបបរទៀតឡើយ (២ពង្សាវតារក្សត្រ៤:៤០-៤១)។**

ហោរាអេលីសេក៏យកម្សៅទៅបង់នៅក្នុងបបរពុលនោះ ហើយគ្រប់គ្នាអាចបរិភោគបបរពុលនោះដោយមិនមានគ្រោះថ្នាក់អ្វីដល់ខ្លួនគេ។

## មនុស្ស១០០នាក់បរិភោគនំបុ័ងម្តៃដុំឆ្អែតស្កប់ស្កល់

មានមនុស្សម្នាក់ចង់ធ្វើតាមក្រឹត្យវិន័យរបស់លោកម៉ូសេ។ បុរសនោះនាំយកនំប៉័ងម្តៃដុំ ដែលធ្វើពីម្សៅផលដំបូង យកមកជូនហោរាអេលីសេ។ នៅក្នុងនគរអ៊ីស្រាអែល មិនមានពួកសង្ឃដែលមានខ្សែស្រឡាយជាប់ជាមួយនឹងលោកលេវីទៀតទេ ពីព្រោះស្តេចយេរ៉ូបោមបានបណ្តេញគេពីនគរអស់ហើយ។ ហោរាអេលីសេមានការសប្បាយចិត្តយ៉ាងខ្លាំង ពីព្រោះក្នុងពេលនេះ ពួកសិស្សសាលាគម្ពីរទាំងអម្បាលមាណមិនមានអ្វីបរិភោគ។ លោកបង្គាប់អោយអ្នកដែលយកនំប៉័ងម្តៃដុំមកជូនលោក រៀប

អោយមនុស្ស១០០នាក់បរិភោគ។ អ្នកដែលយកនំបុ័ងមកជូនលោកយល់ថា នំបុ័ងម្ភៃដុំមិនអាចធ្វើអោយមនុស្ស១០០នាក់បរិភោគបានឆ្អែតស្កប់ស្កល់ឡើយ។ ហោរាអេលីសេបង្គាប់អោយយកនំបុ័ងម្ភៃដុំនោះទៅអោយមនុស្ស១០០នាក់បរិភោគចុះ។

> **៤៣"អ្នកបំរើលោកសួរថា តើធ្វើដូចម្ដេចឱ្យខ្ញុំដាក់តែប៉ុណ្ណេះ ឱ្យ**
> **មនុស្ស១០០នាក់បរិភោគបាន តែលោកបង្គាប់ថា ចូរចែកឱ្យ**
> **គេបរិភោគទៅ ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះថា គេនឹង**
> **បរិភោគឆ្អែត ហើយនឹងនៅមានសល់ផង**
> **៤៤"ដូច្នេះ គាត់ក៏ដាក់**
> **ឱ្យគេបរិភោគ ហើយគេបានឆ្អែត រួចនៅមានសល់ ដូចជាព្រះយេ**
> **ហូវ៉ាបានមានបន្ទូលហើយ (២ពង្សាវតារក្សត្រ៤:៤៣-៤៤)។**

ហេតុការណ៍ដែលកើតខាងលើ ជាហេតុការណ៍ដែលមានលក្ខណៈស្រដៀងជាមួយនឹងព្រះអម្ចាស់យេស៊ូវ ដែលទ្រង់ចំអែតលើកទីមួយ ដល់មនុស្ស៤០០០នាក់ ហើយលើកទីពីរដល់មនុស្ស៥០០០នាក់ ដោយសារតែនំបុ័ងប៉ុន្មានដុំ ហើយនិងត្រីប៉ុន្មានកន្ទុយប៉ុណ្ណោះ។

យើងស្លេះការសិក្សាគម្ពីរ២ពង្សាវតារក្សត្រត្រឹមណោះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"